ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៩១១ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យអនុវត្ត

## គោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី

08. 01. 2015

បណ្ឌិត ហ៊ែល ចំរើន

9.1.15

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ខែមករា ឆ្នាំ២០១២ ដែលប្រកាសដាក់ឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណៈនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ



លេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញប្រកាស លេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាស លេខ ២៣៧សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៥៨៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីបេសកកម្មក្នុងនិងក្រៅប្រទេស
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ដូចមានភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដែលអនុវត្តថវិកាកម្មវិធី។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ខែ ធ្នូ ឆ្នាំ២០១៤

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**របាយការណ៍**

**ស្តីពី**

**លទ្ធផលមួយឆ្នាំនៃការអនុវត្តកំណែទម្រង់ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**សម្រាប់ឆ្នាំ២០១៤**

## ក. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៥ នៃរដ្ឋសភា ដែលកើតចេញពីការបោះឆ្នោតដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ បានដាក់ចេញ នូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បី **កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច នៃកម្មវិធីនយោបាយរបស់ខ្លួន។ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥ រួមជាមួយគ្នា គឺជាឯកសារក្របខណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល បានដាក់ចេញនូវគោលនយោបាយចំនួនពីរ ដើម្បីគាំទ្រការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ឱ្យសម្រេចបានតាមគោលដៅស្ទូចនាករសមិទ្ធកម្មគន្លឹះ ក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាការងារកែទម្រង់ដែលស្ថិតក្នុងដែនសមត្ថកិច្ចនិងក្រោមការទទួលខុសត្រូវរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ គោលបំណងគោលនយោបាយទាំងពីរ រួមមាន÷

**គោលបំណងគោលនយោបាយទី១÷ គ្រប់គ្រងសេដ្ឋកិច្ច និងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ**

**គោលបំណងគោលនយោបាយទី២÷ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ។**

ការងារកែទម្រង់ដែលដឹកនាំអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ២០០៤។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានចែកចេញជា ៤ ដំណាក់កាល គឺ÷

- ដំណាក់កាលទី១ (២០០៤-២០០៨) ÷ ភាពជឿទុកចិត្តបាននៃថវិកា
- ដំណាក់កាលទី២ (២០០៩-២០១៥) ÷ គណនេយ្យភាពហិរញ្ញវត្ថុ
- ដំណាក់កាលទី៣ (២០១៦-២០២០) ÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ
- ដំណាក់កាលទី៤ (២០២១-២០២៥) ÷ គណនេយ្យភាពចំពោះសមិទ្ធកម្ម។

បច្ចុប្បន្ន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំពុងស្ថិតនៅក្នុងដំណាក់កាលអន្តរកាល ដែលត្រូវបានអនុវត្ត តាមរយៈផែនការសកម្មភាព ដំណាក់កាលទី២ ថ្មី (CAP 2 new) ដើម្បីសម្រេចបញ្ចប់ដំណាក់កាលទី២ គឺ **ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ** ក្នុងគោលដៅឈានទៅអនុវត្តដំណាក់កាលទី៣ **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## ខ. លទ្ធផលសម្រេចបាន

ក្នុងរយៈពេលមួយឆ្នាំ នៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រេចបានសមិទ្ធផលធំៗ មួយចំនួន តាមផ្នែកនីមួយៗ ដូចខាងក្រោម÷

### ១. ភាពជឿទុកចិត្តបាននៃថវិកា

### ១.១. លទ្ធផលលើសូចនាករសមិទ្ធកម្មគន្លឹះ

សូចនាករសមិទ្ធកម្មគន្លឹះលើភាពជឿទុកចិត្តបាននៃថវិកា ដែលត្រូវបានដាក់ចេញបានសម្រេចជាលទ្ធផលដូចតទៅ÷

- **សូចនាករទី១** គឺការប្រមូលចំណូលក្នុងស្រុក សម្រាប់ឆ្នាំ២០១៤ អនុវត្តបាន ១០៣,២% កើនលើសឆ្នាំ២០១៣ ប្រមាណ ០,៧%។ ចំណូលប្រចាំឆ្នាំ២០១៤ ធៀបនឹងច្បាប់ហិរញ្ញវត្ថុ សម្រេចបានដូចខាងក្រោម÷
  - ចំណូលពន្ធគយ សម្រេចបានប្រមាណ ១០៧%
  - ចំណូលពន្ធដារ សម្រេចបានប្រមាណ ១០៧%
  - ចំណូលសារពើពន្ធផ្សេងៗទៀត សម្រេចបាន ៨៩%
  - ចំណូលមិនមែនសារពើពន្ធ សម្រេចបាន ៨៨%
  - ចំណូលមូលធន សម្រេចបាន ៤០%។
- **សូចនាករទី២** ដែលគោលដៅបានកំណត់ពីបំណុលកកស្ទះមិនឱ្យលើសពី ២% នៃចំណាយសរុប។ ការអនុវត្តជាក់ស្តែងនៅក្នុងរយៈពេល ៥ឆ្នាំ ចុងក្រោយនេះ បំណុលកកស្ទះត្រូវបានលុបបំបាត់ពោលគឺសាច់ប្រាក់ត្រូវបានធានាសម្រាប់ការចំណាយទាំងស្រុង។ បំណុលកកស្ទះ គួរត្រូវបានធ្វើការតាមដានត្រួតពិនិត្យជាបន្តទៀត បើទោះបីស្ថានភាពសាច់ប្រាក់ត្រូវបានធានាសម្រាប់ការចំណាយទាំងស្រុងយ៉ាងណាក៏ដោយ ព្រោះការកំណត់តាមដាននេះគឺជាមធ្យោបាយក្នុងការវាស់វែងលើភាពជឿទុកចិត្តបាននៃថវិកាទាំងក្នុងស្ថានភាពវិជ្ជមាន និងទាំងក្នុងស្ថានភាពអវិជ្ជមាន។
- **សូចនាករទី៣** ដែលគោលដៅបានកំណត់ការអនុវត្តចំណាយនៅឆ្នាំ២០១៤ មិនត្រូវតិចជាង ៩៦%។ ការអនុវត្តជាក់ស្តែងក្នុងឆ្នាំ២០១៤ ការអនុវត្តចំណាយសម្រេចបាន ៩៤% ទាបជាងគោលដៅប្រមាណ ២% និងទាបជាងការអនុវត្តនៅឆ្នាំ២០១៣ ប្រមាណ ២,១%។
- **សូចនាករទី៤** កំណត់ពីចំណាយតាមប្រភេទ ដែលរួមមាន បៀវត្ស ទំនិញនិងសេវា និងចំណាយមូលធន។ សម្រាប់ឆ្នាំ២០១៤ ចំណាយបៀវត្សអនុវត្តបាន ៨៦,៣%; ទំនិញនិងសេវា អនុវត្តបាន ៨៨,៧% និងចំណាយមូលធន អនុវត្តបាន ១០១,៣%។ ការអនុវត្តចំណាយបៀវត្សសម្រាប់ឆ្នាំ២០១៤ ទាបជាងគោលដៅ ដោយសារការអនុវត្តការបើកបៀវត្សតាមប្រព័ន្ធធនាគារ និង ការលុបបំបាត់ពីតារាងបៀវត្សនូវឈ្មោះមន្ត្រីខ្មោច មន្ត្រីអវត្តមានរយៈពេលយូរ និងមន្ត្រីមានឈ្មោះស្ទួន ដើម្បីពង្រឹងសុក្រឹតភាពចំណាយនិងបង្កើនប្រសិទ្ធភាពនៃការបំពេញមុខងាររបស់មន្ត្រីរាជការ។ រីឯចំណាយលើទំនិញនិងសេវា ទាបជាងគោលដៅសម្រាប់ឆ្នាំ២០១៤ ដោយសារ ការធ្វើវិចារណកម្មចំណាយកាន់តែសុក្រឹតជាងមុន។
- **សូចនាករទី៥** ដែលកំណត់ពីភាគរយនៃចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ រួមចំណែកទៅក្នុង ផ.ស.ស ត្រូវមានកំណើន ០,៥%។ ការអនុវត្តនៅឆ្នាំ២០១៤ ចំណូលសារពើពន្ធ អនុវត្តបាន ១០៦,៥% និងចំណូលមិនមែនសារពើពន្ធ ៨៨,១% កើនលើសការអនុវត្តក្នុងឆ្នាំ២០១៣ ចំនួន ៧% សម្រាប់ចំណូល

សារពើពន្ធ។ រីឯការអនុវត្តចំណូលមិនមែនសារពើពន្ធនៅឆ្នាំ២០១៤ ថយចុះជាងការអនុវត្តនៅឆ្នាំ២០១៣ ចំនួន ៣៥%។ ចំណូលក្នុងស្រុក សម្រាប់ឆ្នាំ២០១៤ មានការកើនឡើងធៀបនឹងឆ្នាំ២០១៣ ដោយសារ÷

- ការកើនឡើងនៃចំណូលពន្ធគយប្រមាណ ២៦% ក្នុងនោះ÷
  - អាករពិសេសលើទំនិញនាំចូល កើនឡើង ៤០%
  - អាករលើតម្លៃបន្ថែមលើទំនិញនាំចូល កើនឡើង ២០%
  - ពន្ធពីការនាំចូលនិងកំរ៉ៃយកមុនពីការងារគយក្នុងការនាំចូល កើនឡើង ៣៣%
  - ពន្ធលើការនាំចូលផលិតផលប្រេងកាត កើនឡើង ៧%
  - ពន្ធលើការនាំចូលផលិតផលសម្រាប់ថែទាំផ្លូវថ្នល់ កើនឡើង ៧%។
- ការកើនឡើងនៃចំណូលពន្ធពន្ធដារ ប្រមាណ ១៨% ក្នុងនោះ÷
  - ពន្ធលើប្រាក់ចំណេញ កើនឡើង ២៤%
  - ពន្ធលើប្រាក់បៀវត្ស កើនឡើង ២៩%
  - ពន្ធលើផលទុនដីធ្លី ផ្ទះសម្បែង កើនឡើង ៣៧%
  - អាករពិសេសលើទំនិញក្នុងស្រុក កើនឡើង ១៣%
  - អាករលើតម្លៃបន្ថែម កើនឡើង ៨%។

❖ **សូចនាករទី៦** គឺការពង្រឹងគណនីទោលរតនាគារ។ គិតចាប់តាំងពីឆ្នាំ២០០៨ មក គណនីទោលរតនាគារ ត្រូវបានពង្រឹងជាបណ្តើរៗ។ គណនីដែលក្រសួង ស្ថាប័ននានាបានបើកត្រូវបានបិទ និងងាកមកប្រើប្រាស់ គណនីទោលរតនាគារ សម្រាប់រាល់ប្រតិបត្តិការចំណូលនិងចំណាយ។ គណនីតាមធនាគារចំនួន ១.៧៣៥ គណនី ត្រូវបានបិទក្នុងប៉ុន្មានឆ្នាំកន្លងទៅ ហើយរហូតមកដល់ពេលនេះ មិនមានការបិទគណនីទៀតទេ ដោយសារមិនមានការបើកគណនីថ្មីដោយគ្មានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឡើយ។ ដោយឡែក អគ្គនាយកដ្ឋានរតនាគារជាតិនឹងបន្តតាមដានទៀត ជាពិសេសគណនីគម្រោងរបស់ដៃគូអភិវឌ្ឍន៍ដែលអស់សកម្មភាពជាដើម។

### ១.២. លទ្ធផលនៃសកម្មភាពគន្លឹះ

❖ ការពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល

- បានកំណត់បញ្ហាប្រឈមពាក់ព័ន្ធនឹងទិន្នន័យនិងព័ត៌មានដែលទាក់ទងនឹងមូលដ្ឋានគិតពន្ធ ដើម្បីកែលម្អម៉ូដែលព្យាករណ៍ចំណូល
- បានរៀបចំនិងអនុម័ត យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨។

❖ ការពង្រឹងការគ្រប់គ្រងបំណុល

- បានរៀបចំសេចក្តីព្រាងបច្ចុប្បន្នកម្មយុទ្ធសាស្ត្រគ្រប់គ្រងបំណុល ២០១៤-២០១៨
- បានធ្វើបច្ចុប្បន្នកម្មរបាយការណ៍ស្តីពីការវិភាគចីរភាពបំណុល (DSA)។

❖ ពង្រឹងការគ្រប់គ្រងសាច់ប្រាក់និងគណនីធនាគារ

- បានបិទគណនីក្រៅប្រព័ន្ធគណនីទោលរតនាគារជាតិ (Treasury Single Account) នៅធនាគារជាតិ និងធនាគារពាណិជ្ជ ដែលមិនមានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានធ្វើការទូទាត់ចំណាយនៅថ្នាក់កណ្តាលតាមប្រព័ន្ធធនាគារ ១០០%។

## ២. គណនេយ្យភាពហិរញ្ញវត្ថុ

- ការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មីនិងប្លង់គណនេយ្យថ្មី
  - បានរៀបចំគោលការណ៍ណែនាំស្តីពីចំណាត់ថ្នាក់មាតិកាថវិកា និង បានដាក់បញ្ចូលចំណាត់ថ្នាក់ទាំង៧ (ចំណាត់-ថ្នាក់ភូមិសាស្ត្រ រដ្ឋបាល សេដ្ឋកិច្ច កម្មវិធី មុខងារ ប្រភពធនធាន និងគម្រោង) ទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីត្រៀមដាក់ឱ្យអនុវត្ត (Go Live) នៅខែកក្កដា ឆ្នាំ២០១៥។
- ការដាក់ឱ្យអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មី
  - បានបណ្តុះបណ្តាលមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសា-ធារណៈ (FMIS)
  - បានបណ្តុះបណ្តាលមន្ត្រីនៃក្រុមការងារគ្រប់គ្រងគម្រោង FMIS លើការគ្រប់គ្រងមូលដ្ឋានទិន្នន័យ (Database)
  - បានរៀបចំឯកសារនីតិវិធីអនុវត្តការងារអនាគត (To-Be Business Process)
  - បានរៀបចំ សេចក្តីព្រាងឯកសារវាយតម្លៃផលប៉ះពាល់សម្រាប់គម្រោង FMIS។
- ការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព
  - បានរៀបចំស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុផ្អែកលើមូលដ្ឋានសាច់ប្រាក់
  - បានរៀបចំនិងអនុម័ត សេចក្តីព្រាងសារាចរណែនាំស្តីពីបញ្ជីសារពើភ័ណ្ឌ។
- ពង្រឹងនិងបង្កើនភាពគ្រប់ជ្រុងជ្រោយនិងសមាហរណកម្មថវិកា
  - បានរៀបចំ កែសម្រួលលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃដាក់ពិន្ទុនិងវិធីសាស្ត្រចាត់ថ្នាក់លើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា
  - បានរៀបចំផែនការកែលម្អទិន្នន័យលើផ្នែកហិរញ្ញប្បទានពីក្រៅប្រទេស (Disbursement of Foreign Financing)
- ពង្រឹងការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច
  - បានរៀបចំអង្គភាពសវនកម្មនៅតាមក្រសួង-ស្ថាប័ន ដែលពុំទាន់បង្កើត ឱ្យស្របតាមនីតិវិធី/លក្ខណៈវិនិច្ឆ័យសមស្របតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  - បានរៀបចំផែនការសវនកម្មនិងអធិការកិច្ចប្រចាំឆ្នាំ របស់ក្រសួង ស្ថាប័ន។

## ៣. ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់

- ការពង្រឹងនិងពង្រីកការអនុវត្តថវិកាតាមកម្មវិធី
  - បានរៀបចំសៀវភៅណែនាំថវិកាកម្មវិធីតាមវិស័យ
  - បានបណ្តុះបណ្តាលមន្ត្រីនៃក្រសួង ស្ថាប័ន អំពីការរៀបចំនិងការអនុវត្តថវិកាកម្មវិធី សរុបចំនួនប្រមាណ ២.០០០នាក់
  - បានដាក់ឱ្យក្រសួងចំនួន ១០ ដើម្បីអនុវត្តថវិកាកម្មវិធីពេញលេញ នៅឆ្នាំ២០១៥ រួមមាន÷ ក្រសួង អប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងកិច្ចការនារី, ក្រសួងយុត្តិធម៌, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការនិងដឹកជញ្ជូន។

❖ រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាព (រវាងនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័ន និងនៅក្នុងក្របខណ្ឌក្រសួង ស្ថាប័ន)

- បានរៀបចំគោលការណ៍ណែនាំស្តីពីការដាក់ឱ្យអនុវត្តសាកល្បងអង្គភាពថវិកា
- បានដាក់ឱ្យក្រសួងទាំង១០ ដែលត្រូវអនុវត្តថវិកាកម្មវិធីពេញលេញ នៅឆ្នាំ២០១៥ រៀបចំនិងដាក់ឱ្យអនុវត្ត អង្គភាពថវិកា

❖ ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ

- បានកែសម្រួលនិងកំណត់លិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំ និងការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានស្រាប់
- បានរៀបចំសេចក្តីព្រាងគោលនយោបាយស្តីពីការប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានរៀបចំសេចក្តីព្រាងឯកសារទស្សនទានស្តីពីឧបករណ៍វិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានរៀបចំផែនការកសាងសមត្ថភាពមន្ត្រីទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសទាក់ទិនទៅនឹងការ អនុវត្ត FMIS។

**៤. ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព**

❖ បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាពនិងវិធានការលើកទឹកចិត្ត

បានរៀបចំយន្តការនិងអភិក្រមថ្មីស្តីពីការផ្តល់ការលើកទឹកចិត្តដែលមានលក្ខណៈសមធម៌និងសង្គតិភាព តាមរយៈ ការរៀបចំលិខិតបទដ្ឋានគតិយុត្ត ពោលគឺ ប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និង សារាចរ លេខ ០០៨ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ព្រមទាំងការបង្កើតគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិង ផ្តល់ការលើកទឹកចិត្ត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្តល់ការលើកទឹកចិត្ត នៃអគ្គនាយកដ្ឋាន/អង្គភាព។

**គ. បញ្ហាប្រឈម**

សម្រាប់ឆ្នាំ២០១៤ បញ្ហាប្រឈមនៃការអនុវត្តការងារកែទម្រង់ មានជាអាទិ៍ ដូចតទៅ៖

- នីតិវិធីនៃការងារនិងការធ្វើលទ្ធកម្មសាធារណៈ មានលក្ខណៈយូរ
- ការងាររៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ជាការងារថ្មីនិងមានលក្ខណៈ បច្ចេកទេសស្មុគស្មាញ
- ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការបណ្តុះបណ្តាល និង ការរៀបចំផែនការកសាងសមត្ថភាព នៅមានកម្រិត
- កង្វះទិន្នន័យដើម្បីកែលម្អម៉ូដែលព្យាករណ៍ចំណូល និងធ្វើការវិភាគចីរភាពបំណុល
- ការរៀបចំសកម្មភាពនិងការកំណត់សូចនាករ មិនទាន់មានភាពសុក្រឹតភាពនិងសង្គតិភាពពេញលេញ ឱ្យឆ្លើយ តបទៅនឹងចង្កោមសកម្មភាពនិងគោលបំណងដែលបានកំណត់
- ភាពជាម្ចាស់និងការទទួលខុសត្រូវលើការងារកែទម្រង់ នៅមានកម្រិត
- កិច្ចសហការនិងការផ្លាស់ប្តូរព័ត៌មាន ព្រមទាំងការសម្របសម្រួលរវាងអង្គភាព និង ស្ថាប័ន នៅមិនទាន់ប្រសិទ្ធ-ភាពនិងស័ក្តិសិទ្ធភាព។

**ឃ. ការងារត្រូវធ្វើបន្ត**

- បន្តពង្រឹងការរៀបចំម៉ូដែលព្យាករណ៍ចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធ
- បន្តរៀបចំនិងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធ
- បញ្ចប់ការរៀបចំគោលការណ៍ណែនាំស្តីពីនីតិវិធីនៃការអនុវត្តថវិកាកម្មវិធី
- គួររៀបចំការវាយតម្លៃលើសមិទ្ធកម្មនៃការបណ្តុះបណ្តាលកន្លងមក និង ការរៀបចំឱ្យមានយន្តការនិងវិធីសាស្ត្ររួមនៃការវាយតម្លៃតម្រូវការបណ្តុះបណ្តាលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បន្តពង្រឹងការរៀបចំសកម្មភាពនិងការកំណត់សូចនាករ ដែលមិនទាន់មានភាពសុក្រឹតភាពនិងសង្គតិភាពពេញលេញ ឱ្យឆ្លើយតបទៅនឹងចង្កោមសកម្មភាពនិងគោលបំណង ដែលបានកំណត់ក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី២ ថ្មី
- ពង្រឹងនិងពន្លឿនការងារនៅសេសសល់ ដើម្បីគាំទ្រដល់ការរៀបចំនិងការអនុវត្តគម្រោង FMIS ប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព ដូចបានកំណត់។

**ង. សេចក្តីសន្និដ្ឋាន**

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឈានពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត ដោយជោគជ័យ ទោះបីជាបានជួបប្រទះបញ្ហាប្រឈមដ៏ស្រួចស្រាលមួយចំនួនដោយចៀសមិនរួចក៏ដោយ។ ក្នុងន័យនេះ ភាពជឿទុកចិត្តបាននៃថវិកា ត្រូវបានធានា តាមរយៈការពង្រឹងការគ្រប់គ្រងនិងការប្រមូលចំណូល ជាពិសេសការដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨។ ចំណែកឯ គណនេយ្យភាពហិរញ្ញវត្ថុត្រូវបានពង្រឹងជាបណ្តើរៗ តាមរយៈការត្រៀមដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី ប្លង់គណនេយ្យថ្មី អង្គភាពថវិកា និងថវិកាកម្មវិធីពេញលេញនៅក្រសួងទាំង១០ ព្រមទាំងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំពុងស្ថិតនៅលើគន្លងដ៏ត្រឹមត្រូវ ព្រោះការអនុវត្តដំណាក់កាលទី២ ដែលផ្តោតលើការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ កំពុងស្ថិតក្នុងដំណាក់កាលសម្រេចបញ្ចប់ ដើម្បីត្រៀមចាប់ផ្តើមដំណាក់កាលទី៣ ក្នុងឆ្នាំ២០១៦ ខាងមុខ តាមការគ្រោងទុក។ ជាលទ្ធផល កម្មវិធីកែទម្រង់នេះ បានបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការប្រមូលចំណូល និង វិចារណកម្មនៃការអនុវត្តចំណាយ និងបានផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលដោះស្រាយនូវបញ្ហាអាទិភាពនិងចាំបាច់នានា ដូចជា ការដំឡើងបៀវត្ស និង ការដោះស្រាយផលវិបាកដែលកើតចេញពីគ្រោះធម្មជាតិ និង បញ្ហាវិវាទព្រំដែន ជាដើម។

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាន់តែមានលក្ខណៈស៊ីជម្រៅនិងស្មុគស្មាញជាងមុន ស្របពេលដែលបញ្ហាប្រឈមមួយចំនួន មិនទាន់ត្រូវបានដោះស្រាយស្រាច់បាច់នៅឡើយ។ ក៏ប៉ុន្តែ បញ្ហាប្រឈមទាំងនេះ បានផ្តល់កាលានុវត្តភាពដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យនិងវាយតម្លៃឡើងវិញ អំពីការអនុវត្តក៏ដូចជាសមិទ្ធកម្មកន្លងមក ដើម្បីអាចដាក់ចេញនូវវិធានការនិងយន្តការថ្មីៗ ក្នុងគោលដៅធានាការសម្រេចបាននូវដំណាក់-កាលនីមួយៗនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាមួយ ដែលមានស្តង់ដារអន្តរជាតិ នៅឆ្នាំ២០២៥។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
លេខ ១៤៤ សហវ.......

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥

**សូមគោរពជូន**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កម្មវត្ថុ** ÷ របាយការណ៍ស្តីពីលទ្ធផលមួយឆ្នាំនៃការអនុវត្តកំណែទម្រង់ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ ២០១៤។

**យោង** ÷ លិខិតលេខ ១៧១១ លស.សរ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំរបាយការណ៍ស្តីពីលទ្ធផលមួយឆ្នាំនៃការអនុវត្តកំណែទម្រង់ របស់ក្រសួង សម្រាប់ឆ្នាំ២០១៤ ដើម្បីគោរពជម្រាបជូនសម្តេចតេជោ នាយករដ្ឋមន្ត្រី សម្រាប់ការចូលក្រាបបង្គំគាល់រាយការណ៍ទូលថ្វាយព្រះករុណាជាអង្គម្ចាស់ជីវិតតម្កល់លើត្បូង ដូចមានគោរពជូនភ្ជាប់មកជាមួយ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។
សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92 Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤
Phone : 855-23-724 664
ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Fax: 855-23-427 798

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ១៧១១ សរ.ជន

រាជធានីភ្នំពេញ ថ្ងៃទី៣០ខែ ធ្នូ ឆ្នាំ ២០១៤

**សូមគោរពជម្រាបជូន**

**[illegible] ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានក្រសួង ស្ថាប័ន**

**កម្មវត្ថុ:** សំណើសុំរបាយការណ៍ ស្តីពីលទ្ធផល "មួយឆ្នាំនៃការអនុវត្តកំណែទម្រង់" ដោយប្រៀបធៀបនឹងខ្លឹមសារក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៥ នៃរដ្ឋសភា។

**យោង :** ខ្លឹមសារនៃកិច្ចប្រជុំដើម្បីរៀបចំរបាយការណ៍ជូនសម្តេចតេជោ នាយករដ្ឋមន្ត្រី សម្រាប់ការចូលក្រាបបង្គំគាល់រាយការណ៍ទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្រោមប្រធានបទ "មួយឆ្នាំនៃការអនុវត្តកំណែទម្រង់" ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

តាមន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមគោរពជម្រាបជូនឯកឧត្តម លោកជំទាវ មេត្តាជ្រាបថា ៖ ដើម្បីឱ្យមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការរៀបចំរបាយការណ៍នេះ សូមឯកឧត្តម លោកជំទាវ ផ្ញើរបាយការណ៍ស្តីពីលទ្ធផល "មួយឆ្នាំនៃការអនុវត្តកំណែទម្រង់" ក្នុងវិស័យដែលជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុក ដោយធ្វើការប្រៀបធៀបទៅនឹងខ្លឹមសារដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៥ នៃរដ្ឋសភា មកទីស្តីការគណៈរដ្ឋមន្ត្រី យ៉ាងយូរ បំផុតត្រឹមថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៥នេះ។

សូមឯកឧត្តម លោកជំទាវ មេត្តាទទួលនូវការគោរពដ៏ស្មោះអស់ពីចិត្ត។

**ជ. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**បណ្ឌិត ហ៊ីង ថូរ៉ាក់ស៊ី**

**ចម្លងជូន**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- នាយកដ្ឋានសរុប
- ឯកសារ កាលប្បវត្តិ

**បញ្ជាក់ លេខទូរស័ព្ទទំនាក់ទំនង:**
- ០១២ ៥៦៦ ១៦៨
- ០១២ ៧៩១ ៨៨៨

31.12.2014

05-01-2015